ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

# ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.)

ECONOMIC, SOCIAL AND CULTURAL COUNCIL (ECOSOCC)







# វិភាគស្ថានភាព

# សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ប្រចាំខែកក្កដា ឆ្នាំ២០២០

# វិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា
# ប្រចាំខែកក្កដា ឆ្នាំ២០២០*

របាយការណ៍វិភាគនេះជាលទ្ធផលនៃកិច្ចប្រជុំចង្អៀតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ក.ស.វ.) លើស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលបានប្រព្រឹត្តទៅនាថ្ងៃព្រហស្បតិ៍ ៨រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០ ក្រោមអធិបតីភាព **ឯកឧត្តមទេសរដ្ឋមន្ត្រី យឹម ណុលឡា** ប្រធានក.ស.វ. ដែលសមាសភាពចូលរួមមានគណៈប្រតិបត្តិក.ស.វ. និងក្រុមការងារវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ហើយការរៀបចំរបាយការណ៍នេះដោយពឹងផ្អែកលើមូលដ្ឋានព័ត៌មាន ទិន្នន័យពីក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងមតិយោបល់ដែលជាធាតុចូលផ្សេងៗទៀតពីថ្នាក់ដឹកនាំ ទីប្រឹក្សាបច្ចេកទេស សមាជិក សមាជិកានៃក.ស.វ. ក្រសួងស្ថាប័នពាក់ព័ន្ធ និងមន្ត្រីអគ្គលេខាធិការដ្ឋាននៃក.ស.វ. តាមប្រព័ន្ធតេលេក្រាម។

## ១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងអត្រាប្តូរប្រាក់(តារាង១)

➡ នាខែកក្កដា ឆ្នាំ២០២០សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង០,៤% ធៀបនឹងខែមុននិង កើនឡើង៣,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| ម្ហូបអាហារ | +៥,១% | សាច់ជ្រូក | +១២,២% |
| ម្ហូបអាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង | +៥,០% | ត្រីស្រស់ | +៧,៩% |
| ភោជនីយដ្ឋាន | +៤,៨% | សាច់គោ | +៤,៣% |
| ទំនិញ និងសេវាកម្មផ្សេងៗ | +៤,២% | អង្ករ | +៣,៥% |
| ការសិក្សា | +៣,៨% | ផ្លែឈើ | +៣,០% |
| សំលៀកបំពាក់ និងស្បែកជើង | +២,៧% | សាច់មាន់ | +២,៧% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | +១,៩% | បន្លែ | +២,៦% |
| គ្រឿងសង្ហារឹម និងសម្ភារៈប្រើប្រាស់ | +០,៦% | | |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៨–២០២០

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា P | កញ្ញា P | តុលា P | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០២០ | ដូចគ្នាឆ្នាំមុន | ៣,៦% | ២.៧% | ២,៨% | ១,៩% | ២,៤% | ៣,២% | ៣,១% | ៣,១% | ៣,៤% | ៣,៤% | | | |
| | មុន | ០,៥% | -០,១% | ០,៤% | -០,៦% | ០,៦% | ០,៤% | ០,៤% | ០,៥% | ០,៣% | -០,២% | | | |
| ២០១៩ | ដូចគ្នាឆ្នាំមុន | ១,៥% | ២,០% | ២,២% | ២,១% | ២,០% | ១,៤% | ២,២% | ២,១% | ១,៧% | ១,៣% | ១,៨% | ៣,១% | ១,៩% |

---

* ការវិភាគជាសំណោរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឱ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឱ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | មុន | -0,0២% | 0,៨% | 0,៣% | 0,៣% | 0,២% | -0,៤% | 0,៥% | 0,៦% | -0,0៣% | -0,១% | 0,១% | 0,៨% | |
| ២0១៨ | ដូចគ្នាឆ្នាំមុន | ២,0% | ២,៣% | ២,៣% | ២,៤% | ២,៩% | ២,៩% | ២,៣% | ២,៦% | ២,៦% | ៣,១% | ២,៥% | ១,៦% | ២,៥% |
| | មុន | 0,១% | 0,៤% | 0,0៤% | 0,៥% | 0,៣% | 0,១% | -0,៣% | 0,៧% | 0,៣% | 0,៣% | -0,៣% | 0,១% | |

P: តួលេខខែសីហា ខែកញ្ញា និងខែតុលា ២0២0 ជាតួលេខព្យាករណ៍ (តាមវិធីសាស្រ្ត DECOMPOSITION)

ក្រាហ្វ ១.១. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់







តារាង១.៣. អត្រាប្តូរប្រាក់

| *ប្រភេទ* | *កក្កដា* ២0២0 | *មិថុនា* ២0២0 | *កក្កដា*២0១៩ | *ប្រភេទ* | *កក្កដា* ២0២0 | *មិថុនា* ២0២0 | *កក្កដា* ២0១៩ |
|---|---|---|---|---|---|---|---|
| **រ/ដុល្លារ** | ៤0៩៩រ/១$ | ៤0៩៣រ/១$ | ៤0៨៦រ/១$ | **បាត/ដុល្លារ** | ៣១,៣បាត/១$ | ៣0,៩បាត/១$ | ៣0,៨បាត/១$ |
| **រ/បាត** | ១៣១រ/១បាត | ១៣៣រ/១បាត | ១៣៣រ/១បាត | **ដុង/ដុល្លារ** | ២៣១៥១ដុង/១$ | ២៣១៧៥ដុង/១$ | ២៣២00ដុង/១$ |
| **រ/ដុង** | 0,១៧៧រ/១ដុង | 0,១៧៧រ/១ដុង | 0,១៧៦រ/១ដុង | **យ័ន់/ដុល្លារ** | ៧,0 យ័ន់/១$ | ៧,១ យ័ន់/១$ | ៦,៩ យ័ន់/១$ |

## ២. ស្ថានភាពថវិកាជាតិ( តារាង២ )

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែកក្កដា ឆ្នាំ២0២0 ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន ១ ៣៥៩,៧ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៣៣៩,៩ លានដុល្លារ (*មធ្យមប្រចាំខែ ៨៨,៨% នៃផែនការ*) ក្នុងនោះចំណូលចរន្តចំនួន ១ ៣៣៦,៣ ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ ៣៣៤,១ លានដុល្លារ (*មធ្យមប្រចាំខែ ៨៨,៩% នៃផែនការ*) និងចំណូលមូលធនមានចំនួន ២៣,៤ ប៊ីលានរៀល ។

➢ ចំណូលថវិកាជាតិ ថយចុះ៧,១% ធៀបនឹងខែមុននិង ថយចុះ៣៧,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ១ ៤៥៩,៥ ប៊ីលានរៀល ថយចុះ:0,៦% ធៀបនឹងខែមុននិង ថយចុះ:២៦,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន (តាមតួលេខ អគ្គនាយកដ្ឋានពន្ធដារនិងអគ្គនាយកដ្ឋានគយ)។ ចំណែកតាមតួលេខរតនាគារជាតិចំណូលសារពើពន្ធមានចំនួន ១ ២២២,២ ប៊ីលានរៀល ថយចុះ:៩,២% ធៀបនឹងខែមុននិង ថយចុះ:២៨,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ចំណូលមិនមែនសារពើពន្ធមានចំនួន ១១៤,១ ប៊ីលានរៀល កើនឡើង១២,៤% ធៀបនឹងខែមុនប៉ុន្តែ ថយចុះ៦៧,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន (តាមតួលេខ រតនាគារជាតិ)។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៨–២០២០
(ប៊ីលានរៀល)




**តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| **ចំណូលសារពើពន្ធ** (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | **ចំណូលមិនមែនសារពើពន្ធ** (តាមតួលេខ រតនាគារជាតិ) (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: :+២,៣% (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (-៣៤,៨%) | ➢អាជ្ញាបណ្ណក្នុងស្រុក : -១០,០% | (+១០៤,០%) |
| | | ➢ កម្រៃការគ្រប់គ្រង និងទិដ្ឋាការនាំចេញ: -៧៧,៨% | (-៨០,៦%) |
| ➢ ចំណូលពន្ធដារ: -៣,៧% (អគ្គនាយកដ្ឋានពន្ធដារ) | (-១៥,១%) | ➢សម្បទានរ៉ែ: +៥៩,២% | (+៤,១%) |
| | | ➢ អាកាសចរណ៍ស៊ីវិល: +៣៦,៩% | (-៩៦,២%) |

**២.២. ចំណាយថវិកាជាតិ** : អនុវត្តបាន ១ ៨៤៤,៩ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៤៦១,២ លានដុល្លារ(*មធ្យមប្រចាំខែ ៦៥,៥% នៃផែនការ*) ក្នុងនោះ ចំណាយចរន្តចំនួន ១ ២១៤,៤ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៣០៣,៦ លានដុល្លារ(*មធ្យមប្រចាំខែ ៨៧,១% នៃផែនការ*) និងចំណាយមូលធនមានចំនួន ៦៣០,៥ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ១៥៧,៦ លានដុល្លារ(*មធ្យមប្រចាំខែ ៣៥,៧% នៃផែនការ*) (តាមតួលេខ រតនាគារជាតិ)។

➢ចំណាយថវិកាជាតិ ថយចុះ២១,៣% ធៀបនឹងខែមុនប៉ុន្តែ កើនឡើង៦,៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្ត ថយចុះ២០,៣% ធៀបនឹងខែមុននិង ថយចុះ១៣,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះមានឱនភាពចំនួន ៤៨៥,២ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ១២១,៣ លានដុល្លារ (តួលេខរតនាគារជាតិ)។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៧–២០១៩
(ប៊ីលានរៀល)



## ៣. ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់ (តារាង៣)

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែកក្កដា ឆ្នាំ២០២០ មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុ **$M_2$** មានចំនួន ១២៧ ៣៣១,៥ ប៊ីលានរៀល មានការកើនឡើង២,៦%ធៀបនឹងខែមុននិងកើនឡើង ១២,៥%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើង$M_2$** ក្នុងខែនេះ ជារួមបណ្ដាលមកពី ការកើនឡើងនៃ រូបិយវត្ថុក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើ ១,២% ប្រាក់បញ្ញើចរន្ត ០,៦% និងប្រាក់បញ្ញើផ្សេងទៀត ៣,៣%។

➢ក្នុងខែនេះ ប្រាក់រៀលនៅក្នុង និងក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើរមានចំនួន១៦,២% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន៨៣,៨% នៃរូបិយវត្ថុ$M_2$។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែកក្កដា ឆ្នាំ២០២០




តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០២០

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅស្ថាប័នទទួលប្រាក់បញ្ញើ | ១៥,៦% | ១៥,៧% | ១៦,៤% | ១៦,៥% | ១៦,៤% | ១៦,២% | ១៦,២% | | | | | |
| រូបិយបណ្ណបរទេសនៅក្នុងធនាគារ | ៨៤,៤% | ៨៤,៣% | ៨៣,៦% | ៨៣,៥% | ៨៣,៦% | ៨៣,៨% | ៨៣,៨% | | | | | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែកក្កដា ២០២០: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




តារាង៣.៣.ការផ្ដល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| ផ្ដល់ដោយ | កក្កដា ២០២០ | មិថុនា ២០២០ | កក្កដា ២០១៩ |
|---|---|---|---|
| ឥណទានផ្ដល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល) | ១១៥ ៥២៥,៥ | ១១៤ ០៧៩,៥ | ៩៧ ១៥៤,២ |
| ក្នុងនោះ ជារៀល | ១៣ ០៩៦,៨ | ១២ ៩៣៥,៥ | ៦ ៦៤០,៧ |
| ឥណទានផ្ដល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ប៊ីលានរៀល) | ២៩ ៧៦០,៣ | ២៩ ២២៥,៦ | ២៦ ៧០៤,៨ |
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៤,២% | ៥,០% | ៥,១% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៣,៤% | ៣,៣% | ៣,៦% |

| | | | |
|---|---|---|---|
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១១,៤% | ៩,៧% | ១០,៣% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ៨,៣% | ៨,០% | ៨,៥% |
| កម្ចីជារៀលនៅហត្ថកសិករ | ១៧,៩% | ១៧,៨% | ១៨,០% |
| កម្ចីជារៀលនៅអម្រឹត | ១៧,៩% | ១៧,៨% | ១៨,០% |
| កម្ចីជារៀលនៅប្រាសាក់ | ១៧,៤% | ១៥,០% | ១៦,០% |

## ៤. ស្ថានភាពកសិកម្ម ឧស្សាហកម្ម ថាមពល សេវាកម្ម និងវប្បធម៌ (តារាង៤)

➡ក្នុងខែកក្កដា ឆ្នាំ២០២០ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន ៨៨,៤ ពាន់តោន កើនឡើង២៦,៩% ធៀបនឹងខែមុននិង កើនឡើង៧,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**រ៉ែ និងថាមពល**:

✓អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ១ ០៣៥,១ GWh មានការ ថយចុះ៣,៦% ធៀបនឹងខែមុនប៉ុន្តែ កើនឡើង០,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ៖

- អគ្គិសនីផ្គត់ផ្គង់ដោយវារីអគ្គិសនីក្នុងស្រុកមានចំនួន ៣១៦,៩ GWh មានការ កើនឡើង៤៦,៦% ធៀបនឹងខែមុន ប៉ុន្តែ ថយចុះ៣៩,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- អគ្គិសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន ៤៧៣,៤ GWh មានការ កើនឡើង១៤,៥% ធៀបនឹងខែមុន និង កើនឡើង ៦០,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- អគ្គិសនីដែលនាំចូលពីប្រទេសជិតខាងដោយ EDCមានចំនួន ២០១,១ GWh មានការ ថយចុះ៤០,៣% ធៀបនឹងខែមុនប៉ុន្តែ កើនឡើង១៤,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- និងអគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀតមានចំនួន ៤៣,៦ GWh មានការ ថយចុះ៥៩,៥% ធៀបនឹងខែមុន ប៉ុន្តែ កើនឡើង៨,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**ឧស្សាហកម្ម**:

តារាង៤.១. ការចុះបញ្ជីរោងចក្រនិងឧស្សាហកម្មធុនតូច និងសិប្បកម្មនៅក្រសួងឧស្សាហកម្ម

| *ប្រភេទ* | *ចំនួន—កក្កដា ២០២០* | *ចំនួន—មិថុនា ២០២០* | *ចំនួន—កក្កដា ២០១៩* |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ១២ | ២២ | ៣២ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១ ៨៦៣ | ១ ៨៦១ | ១ ៦៥៧ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១៦៣ | ៨៨ | ៤ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ១២៧ | ៦៦ | ១៣ |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ១ ៩៩២,០ ពាន់ម$^2$ មានការ កើនឡើង១០៣,៦%ធៀបនឹងខែមុន ប៉ុន្តែថយចុះ ២៦,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង ៤៣៣,២ លានដុល្លារមានការ ថយចុះ៨,៩% ធៀបនឹងខែមុនប៉ុន្តែ កើនឡើង៧២៤,៦% បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម² — កក្កដា ២០២០ | ពាន់ម² —មិថុនា ២០២០ | ពាន់ម² —កក្កដា ២០១៩ |
|---|---|---|---|
| ▪ លំនៅឋាន | ៦៩៥,៨ | ៣៦១,៥ | ៨៨៨,០ |
| ▪ ឧស្សាហកម្ម | ២៩២,០ | ៥៥,៣ | ៥៦៤,៧ |
| ▪ពាណិជ្ជកម្ម | ៥៣៨,៨ | ២៩២,២ | ៤៣៦,២ |
| ▪ ទេសចរណ៍ | ២៤,២ | ២៧,៣ | ២៥៩,៤ |
| ▪ផ្សេងៗ | ០,០ | ០,០ | ០,៩ |
| អនុញ្ញាតសរុប | ១ ៥៥២,០ | ៧៨២,១ | ២ ១៦០,៤ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺលំនៅឋាន ៤៣,៧% និងពាណិជ្ជកម្ម ៣៣,៨% នៃផ្ទៃក្រឡាសរុប។

## ➢សេវាកម្ម

តារាង៤.៣.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន —កក្កដា ២០២០ | ចំនួន—មិថុនា ២០២០ | ចំនួន—កក្កដា ២០១៩ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ២១៦ | ៤៣៧ | ៥០៥ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៤៨ | ៥០ | ៤ |
| សហគ្រាសដែលបានចុះបញ្ជីពន្ធដារ | ៦៨៦ | ៥៩៤ | ១ ២៣៩ |

## ➢ការងារ

តារាង៤.៤. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់— កក្កដា ២០២០ | នាក់— មិថុនា ២០២០ | នាក់— កក្កដា ២០១៩ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបរនិងការងារ) | ៣ ៦២២ | ២ ២២១ | ១ ៩២៦ |
| អ្នកទទួលបានការងារធ្វើតាមរយៈ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងទីភ្នាក់ងារជ្រើសរើសឯកជន | ១៨ ១៣២ | ១៨ ៤២៩ | ១៦ ៨៤៣ |
| អ្នកទទួលបានការងារក្នុងប្រទេស | ១៨ ១២៦ | ១៨ ៤២៩ | ១០ ១៨១ |
| អ្នកទទួលបានការងារក្រៅប្រទេស | ៦ | ០ | ៦ ៦៦២ |

## ➢វិនិយោគ

តារាង៤.៥.គម្រោងវិនិយោគអនុញ្ញាតដោយ ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | កក្កដា ២០២០ | មិថុនា ២០២០ | កក្កដា ២០១៩ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៦៦,៣ | ១៨៥,៩ | ១៨៧,៦ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៣៤,២ | ២៨,៤ | ១០,០ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៣២,១ (១០,៤) | ១២២,២ (៧,១) | ១៧០,៦ (៩១,៤) |
| វិស័យទេសចរណ៍ | ០,០ | ៣៩,២ | ០,០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០,០ | ០,០ | ៧,០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ១០ | ១៥ | ៣៤ |
| បង្កើតការងារ (ពាន់នាក់) | ៥,៤ | ៧,២ | ២២,៧ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប២កំពង់ផែ) មានចំនួន ៨៤៨,១ ពាន់តោន មានការ ថយចុះ១០,៥% ធៀបនឹងខែមុននិង ថយចុះ៦,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ក្នុងនោះ:

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | |
|---|---|
| ▪ កំពង់ផែភ្នំពេញ: -៤,៥% (-៦,៧%) | ▪ កំពង់ផែកំពង់សោម: -១៣,៨% (-៦,៣%) |

## ➢ការចុះបញ្ជី និងចរាចរណ៍

តារាង៤.៧.ការចុះបញ្ជីម៉ូតូ រថយន្ត និងគ្រោះថ្នាក់ចរាចរណ៍

| ប្រភេទ | ចំនួន –កក្កដា ២០២០ | ចំនួន–មិថុនា ២០២០ | ចំនួន–កក្កដា ២០១៩ |
|---|---|---|---|
| ចំនួនម៉ូតូបានចុះបញ្ជី (ពាន់គ្រឿង) | ២៣,៤ | ២៤,៧ | ៤២,៤ |
| ចំនួនរថយន្តគ្រប់ប្រភេទបានចុះបញ្ជី(ពាន់គ្រឿង) | ៧,៣ | ៧,៧ | ១០,៤ |
| ចំនួនគ្រោះថ្នាក់ចរាចរណ៍ (លើក) | ២៥៧ | ២៣៩ | ៣៣៦ |

## ➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ១០,២ | +០,៤% | -៦០,១% |
| ក្នុងនោះទទួល | ៣,៥ | -០,៣% | +១៨,៤% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ១៩,៣ | +១១០,០% | -៧៩,៣% |
| ក្នុងនោះទទួល | ១៩,៣ | +១០៩,៩% | -៦៤,២% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ១០១៤,៩ | +១២,៩% | -២៨,២% |
| ក្នុងនោះហៅចូល | ៤០១,៧ | +១៤,៥% | -២២,២% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៣ ៦៦០,៥ | +៥០,៧% | -៣៤,២% |
| ក្នុងនោះហៅចូល | ៣ ៥៣២,៨ | +៤៧,៥% | -៣៥,៨% |

## ➢ ធ្វើដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍

តារាង៤.៨.អ្នកដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ០,៤ | +១៦,៦% | -៩៦,៦% |
| ភ្ញៀវទេសចរបរទេសទិញប័ណ្ណទស្សនាអង្គរ | ១,៨ | +២,៥% | -៩៨,៨% |
| ភ្ញៀវទេសចរចូលទស្សនា រមណីយដ្ឋានព្រះវិហារ | ១២,៧ | +២៦,៦% | +៣៥,៤% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ០,៨ | +២៤៣,៨% | -៩៩,២% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៣១,៦ | +២៨,៧% | -៩៦,៣% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ២,៥ | +១៨៣,២% | -៩៨,៥% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ២០,៧ | +៦៨,៤% | -៩៥,៩% |
| ✓ តាមផ្លូវអាកាស | ១០,២ | +២៣,៤% | -៩៧,៣% |
| ✓ តាមផ្លូវគោក និងទឹក | ១០,៥ | +១៦១,៥% | -៩១,៤% |

## ៥. ស្ថានភាពជញ្ជូនពាណិជ្ជកម្ម (តារាង៥)

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែកក្កដា ឆ្នាំ២០២០ មានចំនួន ៥ ៨៦៨,៨ ប៊ីលានរៀល (ស្មើនឹង ១ ៤៦៧,២ លានដុល្លារ ស.រ.អា.)ថយចុះ១,០% ធៀបនឹងខែមុននិងថយចុះ១៨,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ៖

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | +២,២% | +២៤,២% | រថយន្តសរុប (ប៊ី.ល.រ) | -១៣,៧% | -៤៩,៨% |
| ប្រេងម៉ាស៊ូត | -១២,០% | -២,៧% | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +១២,៦% | -១៤,៨% |
| ឧស្ម័ន | +២៨,៤% | -៨,៣% | នាំចូលរបស់ស្ថានទូតមិនធ្វើអាជីវកម្ម | -៧៣,៩% | +៣២,២% |
| អគ្គិសនីនាំចូលដោយEDC | -៦៤,១% | -៥៥,៧% | | | |
| ដែកសំណង់ | +៣៥៧,៤% | +៩៤,៨% | | | |
| ស៊ីម៉ង់ត៍ | -១៤,៦% | -៦៧,៤% | | | |

➡ **ការនាំចេញ** ខែកក្កដា ឆ្នាំ២០២០ មានចំនួន **៩ ១៨៥,៨** ប៊ីលានរៀល ស្មើនឹង **២ ២៩៦,៤** លានដុល្លារ ស.រ.អា. (១៥៦,៥% នៃការនាំចូល) មានការកើនឡើង១៩,៩% ធៀបនឹងខែមុន និងកើនឡើង៤៥,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | +២០,៥% | +៦៥,៧% | ផលិតផលនេសាទ | -៧,៨% | +៣៥,២% |
| វាយនភណ្ឌនិងស្បែកជើង | +៤២,១% | +៦,៧% | កៅស៊ូ | +៣៦,៤% | +៥០,១% |
| អង្ករ | -១៧,៩% | +៤,៣% | | | |

# ប្រាសាទកោះកេរ្តិ៍




ក្រុមការងាររៀបចំរបាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

អាសយដ្ឋាន: អគារមិត្តភាព លេខ៨១ មហាវិថីសហព័ន្ធរុស្ស៊ី ខណ្ឌ៧មករា រាជធានីភ្នំពេញ

ទូរស័ព្ទ: ០៨៥ ៧៧៧ ៩៥០ / ០១២ ៦៦២ ៣១៦ ទូរសារ: ០២៣ ២២១ ៩៥០

Email: chyanit168@gmail.com / mamsarith@yahoo.com